**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៦.១៣...០១៨...០០៧...ធ.ក.ព.ម

ទីក្រុងណានីង, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី ការដាក់ផ្សាយអត្រាប្តូរប្រាក់ទ្វេភាគី (រៀលនិងយ័ន់) នៅទីផ្សារអន្តរធនាគារនៅតំបន់ស្វយ័ត Guangxi Zhuang ប្រទេសចិន

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលចិន បានសម្ពោធដាក់ឱ្យដំណើរការដោះដូររវាងប្រាក់រៀល និងប្រាក់យ័ន់ក្នុងទីផ្សារអន្តរធនាគារនៅតំបន់ស្វយ័ត Guangxi Zhuang ប្រទេសចិន។ អត្រាប្តូរប្រាក់ទ្វេភាគីរវាងប្រាក់រៀលនិងប្រាក់យ័ន់ចិន នឹងត្រូវបានផ្សព្វផ្សាយសម្រាប់ធ្វើការដោះដូរដោយផ្ទាល់រវាងប្រាក់រៀលជាមួយនឹងប្រាក់យ័ន់ចិននៅលើទីផ្សារនេះ។ ពិធីនេះត្រូវបានប្រារព្ធឡើងនៅទីក្រុងណានីង ប្រទេសចិន ក្នុងឱកាសនៃវេទិកាកំពូលស្តីពីការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការវិស័យហិរញ្ញវត្ថុអាស៊ាន-ចិនលើកទី៩ ក្រោមអធិបតីភាព ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ឯកឧត្តម Yin Yong ទេសាភិបាលរងធនាគារកណ្តាលចិន និងឯកឧត្តម Peng Qinghua លេខាគណៈកម្មាធិការបក្សតំបន់ស្វយ័ត Guangxi Zhuang ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំនៃអាជ្ញាធររូបិយវត្ថុនិងគ្រឹះស្ថានហិរញ្ញវត្ថុរបស់ចិន និងអាស៊ានជាច្រើនរូបទៀត។

ការដាក់ប្រាក់រៀលនិងប្រាក់យ័ន់ឱ្យដោះដូរនេះ ជាលទ្ធផលនៃការកើនឡើងនៃទំនាក់ទំនងទាំងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ រវាងកម្ពុជានិងចិន និងជំនឿទុកចិត្តមកលើប្រាក់រៀលក៏ដូចជាសេដ្ឋកិច្ចកម្ពុជា ហើយក៏ឆ្លុះបញ្ចាំងផងដែរពីការឆ្លើយតបនឹងសេចក្តីត្រូវការប្រាក់រៀលរបស់ពាណិជ្ជករចិន ដែលអាចនឹងកើនឡើងសម្រាប់ការដោះដូរទ្វេភាគីនាពេលអនាគត។ កន្លងមកប្រទេសចិន ក៏បានជំរុញការប្រើប្រាស់រូបិយវត្ថុជាតិក្នុងពាណិជ្ជកម្មទ្វេភាគីជាមួយប្រទេសដទៃផងដែរ ដូចជា ជាមួយប្រទេសម៉ាឡេស៊ីនិងថៃជាដើម។ ធនាគារជាតិនៃកម្ពុជារំពឹងថា តាមរយៈការប្រើប្រាស់រូបិយវត្ថុជាតិក្នុងសកម្មភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្ម នឹងជួយកាត់បន្ថយហានិភ័យអត្រាប្តូរប្រាក់ លើកកម្ពស់ប្រសិទ្ធភាព សុវត្ថិភាព និងភាពឆាប់រហ័សក្នុងការទូទាត់ ព្រមទាំងបង្កើនលទ្ធភាពឱ្យធនាគារកណ្តាលទាំងពីរចូលរួមកាន់តែសកម្មក្នុងការគាំទ្រការរីកចម្រើនទំនាក់ទំនងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលទាំងអស់នេះនឹងរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងពាណិជ្ជកម្មនៅក្នុងប្រទេសទាំងពីរបន្ថែមទៀតនាពេលអនាគត។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh